ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃអង្គារ ៤កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥។

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

**៣.១** ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៣. ២** សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣០រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៤រូប សរុបចំនួន៣៦រូប។

**៤. របៀបវារៈ៖**

**៤.១** មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

**៤.២** បទបង្ហាញស្តីពី "ការធ្វើនវានុវត្តន៍វិធីសាស្ត្រអប់រំបង្ការការចម្លងមេរោគអេដស៍" ដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៤.៣** មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

**៥.១** ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានថ្លែងនូវមតិស្វាគមន៍ដល់អង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារនៃគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក ដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជាបានធ្លាក់ចុះជាបន្តបន្ទាប់មកនៅត្រឹមតែ ០,៥ % នៅឆ្នាំ២០២៤។ ទន្ទឹមនឹងនេះដែរ **ឯកឧត្តម** ក៏បានលើកផងដែរពីផលប៉ះពាល់នៃការកាត់បន្ថយហិរញ្ញប្បទានពីខាងក្រៅ និងបញ្ហាសង្គ្រាមដែលកំពុងកើតឡើងរវាងថៃ-កម្ពុជា នាពេលបច្ចុប្បន្ននេះ។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបើកនូវកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៧ ឆ្នាំ២០២៥ ក្រោមប្រធានបទ "**ការធ្វើនវានុវត្តន៍វិធីសាស្ត្រអប់រំបង្ការការចម្លងមេរោគអេដស៍**"។

**កិច្ចប្រជុំនេះមានគោលបំណង ដូចខាងក្រោម៖**

១- គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨

២-ផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយនិងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ ឆ្នាំ២០២៤-២០២៨

៣- ផ្សេងៗ

**៥.២** ជាបន្ត **ឯកឧត្តមបណ្ឌិត** ក៏បានបទបង្ហាញស្តីពី "ការធ្វើនវានុវត្តន៍វិធីសាស្ត្រអប់រំបង្ការការចម្លងមេរោគអេដស៍" ដូចតទៅ ៖

ក- គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨៖

- ចក្ខុវិស័យ៖ ធានាថា ប្រទេសកម្ពុជាជាប្រទេសមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងធានាថា ប្រជាជនកម្ពុជាមានសុខភាពល្អ និងរស់នៅប្រកបដោយសុខុមាលភាព គ្មានការភ័យខ្លាចដោយសារជំងឺអេដស៍។
- កម្មវត្ថុ៖ ៣
- គោលដៅ(គគ)៖ ៧
- វិធានការគោលនយោបាយ៖
  - ➢ វិធានការ ពង្រឹងប្រព័ន្ធជាតិឆ្លើយតបជាពហុវិស័យ
  - ➢ វិធានការ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ
  - ➢ វិធានការ បង្រីក ពង្រឹង ពន្លឿនកម្មវិធីថែទាំនិងព្យាបាល
  - ➢ វិធានពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម
  - ➢ បញ្ចប់ការរើសអើងនិងមាក់ងាយ
  - ➢ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធតាមដាននិងវាយតម្លៃ។

ខ- ផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយនិងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ ឆ្នាំ២០២៤-២០២៨៖

- ចក្ខុវិស័យ៖ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ និងគ្មានការមាក់ងាយ និងរើសអើង។
- បេសកកម្ម៖ ធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្នដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន់ និងមានចីរភាព។
- គោលដៅ៖ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាព ដែលធានាថា ជំងឺអេដស៍លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពី ឆ្នាំ២០២៨ តទៅ ដែលមានគោលបំណងចំនួន៤៖

១-ផ្តល់ការបង្ការ ព្យាបាល ថែទាំ និងគាំទ្រទូលំទូលាយ និងមានប្រសិទ្ធភាព តាមរយៈការសម្របសម្រួលល្អ និងប្រើប្រាស់វិធីសាស្ត្រជំរុញការចូលរួមជាពហុវិស័យ។

២-ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាស អំណោយផលឱ្យក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ បានទទួលសេវាមេរោគអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។

៣-កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបដោយសហគមន៍ និងកែលម្អការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល។

៤-ធានាចីរភាពសមិទ្ធផលជាតិនៃការឆ្លើយតបនឹងមេរោគអេដស៍ ដោយការបង្កើនការវិនិយោគជាតិនិងការពង្រឹងប្រព័ន្ធប្រទេសឆ្លើយតបនឹងមេរោគអេដស៍ដោយអភិបាលកិច្ចសម្របសម្រួល និងត្រួតពិនិត្យ។

គ- តាមការវិភាគក្នុងចំណោមករណីឆ្លងមេរោគអេដស៍ ១២០០នាក់ ប្រជាជនទូទៅឆ្លង១២% និងប្រជាជនគន្លឹះ៨៨%។ ការឆ្លងមេរោគអេដស៍នៃប្រជាជនគន្លឹះ៨៨% មាន៖

- ៤៨% ជាក្រុមបុរសរួមភេទជាមួយបុរស
- ១៣% ជាក្រុមដៃគូរួមភេទជាមួយប្រជាជនគន្លឹះ
- ៩% ជាក្រុមបំប្លែងភេទ
- ៧% ជាក្រុមរកស៊ីផ្លូវភេទបុរស
- ៧% ជាក្រុមស្ត្រីបម្រើសេវាកម្សាន្តសប្បាយ
- ២% ជាក្រុមចាក់គ្រឿងញៀន។

ឃ- វិធីសាស្ត្របង្ការមេរោគអេដស៍ ដែលបានបែងចែកជា៣ដំណាក់កាល

ង- វិធីសាស្ត្ររួមបញ្ចូលគ្នានៃការបង្ការមេរោគអេដស៍មានជាអាទិ៍ផ្នែកជីវសាស្ត្រ ផ្នែករចនាសម្ព័ន្ធ និងផ្នែកអាកប្បកិរិយា

ច- ទិសដៅនៃការបង្ការ៖

- ក្តាប់ចំនួនក្រុមគោលដៅឱ្យបានច្បាស់ជាពិសេសយុវជន
- កម្មវិធីបញ្ជ្រាបមេរោគអេដស៍ និងជំងឺអេដស៍ទៅគ្រប់កម្មវិធីសិក្សា
- កម្មវិធីបញ្ចូលមេរោគអេដស៍និងជំងឺអេដស៍ទៅគ្រប់សកម្មភាពបណ្តុះបណ្តាលនិងសិក្ខាសាលា
- កម្មវិធីចុះអប់រំផ្ទាល់ដល់ក្រុមប្រឈមខ្ពស់ ការបង្ការប្រែប ការធ្វើតេស្ត បន្តទៅការព្យាបាល
- អាទិភាពខ្ពស់បំផុតគឺប្រើប្រាស់បណ្តាញសង្គម។

ឯកឧត្តមប្រធានអង្គប្រជុំក៏បានសង្កាត់ធ្ងន់លើក្របខ័ណ្ឌគោលនយោបាយយោងនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ រៀបចំឡើងសម្រាប់រយៈពេល៥ឆ្នាំ។ គោលនយោបាយនេះ បានកំណត់ការងារអាទិភាព និងវិធានការគោលនយោបាយចាំបាច់នានា

ដើម្បីកែលម្អនិងបំពេញបន្ថែមលើចំណុចខ្វះខាតនៃរាល់កម្មវិធី ឈានទៅសម្រេចបានដំណាក់កាលនៃការបញ្ចប់អេដស៍ និងធានាចីរភាពនៃកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣ទៅ២០២៨។ ដើម្បីពង្រឹងប្រព័ន្ធជាតិឆ្លើយតបជាលក្ខណៈពហុវិស័យចំពោះមេរោគអេដស៍និងជំងឺអេដស៍ រាជរដ្ឋាភិបាលបានកំណត់នូវវិធានការគោលនយោបាយ មានដូចជា៖

១- ជំរុញឱ្យរៀបចំឬដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ខណ្ឌ ស្រុក រហូតដល់ឃុំ សង្កាត់។

២- ជំរុញឱ្យរៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ និងតាមវិស័យរៀងៗខ្លួន ក្នុងក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ល។

បន្ថែមពីលើនេះ ដើម្បីឱ្យការឆ្លើយតបលើការអនុវត្តកម្មវិធីអេដស៍ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព រាជរដ្ឋាភិបាលបានកំណត់វិធានការគោលនយោបាយលើចលនាធនធានមួយចំនួនដូចជា៖

១- ធ្វើការវាយតម្លៃលើតម្រូវការជាក់លាក់ និងកៀរគរប្រភពធនធាន សមស្របដើម្បីវិភាជន៍ថវិកាក្នុងការទ្រទ្រង់កម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ឱ្យបានទៀងទាត់និងទាន់ពេលវេលា។

២- ធ្វើវិភាជន៍ថវិកាតាមតម្រូវការចាំបាច់នៃក្រសួង ស្ថាប័ន ដែលមានផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ច្បាស់លាស់ ស្របនឹងលទ្ធភាពថវិកាជាក់ស្តែង។

៣- ជំរុញរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈការរៀបចំផែនការសកម្មភាពនិងថវិកាជាក់លាក់ ស្របនឹងលទ្ធភាពថវិការដ្ឋបាលសាមី។

៤- លើកទឹកចិត្តរដ្ឋបាល ឃុំ សង្កាត់ ប្រើប្រាស់ថវិកាសមាសភាពសេវាសង្គមសមស្របតាមលទ្ធភាពថវិកា ដើម្បីរៀបចំនិងអនុវត្តផែនការ សកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ឱ្យសម្រេចជោគជ័យ។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** ស្នើសុំក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិលើកការងារអេដស៍ចូលក្នុងផែនការរបស់ខ្លួន។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១១:៣០នាទីព្រឹកថ្ងៃខែឆ្នាំដដែលប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| ប្រធានអង្គប្រជុំ | ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន | |
| លោក ឈឹម មិនដារ៉េត | វេជ្ជ. ហួត សេរីវុទ្ធ | ស៊ុំ ផល្លា |